**Media Statement**

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

## ទិវាសេរីភាពសារព័ត៌មានពិភពលោក
## សេចក្តីថ្លែងការណ៍របស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
## លោកស្រី មីហ្សែល បាស្លេទ្បែត
## ៣ ឧសភា ២០២១

សារព័ត៌មានសេរី គ្មានការរិតត្បិត និងឯករាជ្យ គឺជាគ្រឹះនៃសង្គមប្រជាធិបតេយ្យ។ វាអាចនាំមកនូវព័ត៌មានសង្គ្រោះជីវិតនៅក្នុងគ្រាមានវិបត្តិ ផ្តល់នូវមូលដ្ឋានសម្រាប់ការចូលរួមរបស់សាធារណៈជន និងជួយធានាឱ្យមានគណនេយ្យភាព និងការគោរពសិទ្ធិមនុស្ស។

ទិវាសេរីភាពសារព័ត៌មានពិភពលោកគឺជាឱកាសមួយ ដើម្បីអបអរសាទរការងារជាមូលដ្ឋាននេះ។ ជាពិសេសនៅថ្ងៃនេះ ខណៈដែលយើងប្រារព្ធខួបលើកទី ៣០ នៃសេចក្តីប្រកាសទីក្រុងវីនដុក ដែលក្នុងនោះ អ្នកសារព័ត៌មានអាហ្វ្រិកមួយក្រុមបានដាក់ចេញនូវគោលការណ៍សំខាន់ៗសម្រាប់សេរីភាពសារព័ត៌មាន។

ប៉ុន្តែទោះបីជាតួនាទីពាក់ព័ន្ធថ្នាក់ខ្ពស់របស់ពួកគេក៏ដោយ ក៏អ្នកសារព័ត៌មានតែងតែប្រឈមមុខនឹងការវាយប្រហារ ការគំរាមកំហែង ការយាយី និងការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌដោយសារតែការងាររបស់ខ្លួនដែរ។ តួលេខក៏បានបង្ហាញផងដែរនូវអត្រាដ៏គួរឱ្យភ្ញាក់ផ្អើលនៃអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រប្រឆាំងនឹងអ្នកសារព័ត៌មានស្ត្រី រាប់បញ្ចូលទាំង ការយាយីផ្លូវភេទ និងការរំលោភបំពានតាមអនឡាញ។

ចំនួនអ្នកសារព័ត៌មាន និងបុគ្គលិកអ្នកសារព័ត៌មាន ត្រូវបានសម្លាប់ ក្នុងទសវត្សចុងក្រោយនេះ មានជិតមួយពាន់នាក់។ ចំនួនដ៏គួរឱ្យរន្ធត់នៃការវាយប្រហារ រួមមាន តាមរយៈតួអង្គរដ្ឋ ក្រុមប្រដាប់អាវុធ ឬក្រុមឧក្រិដ្ឋជនគឺមានលក្ខណៈកាចសាហាវ ដូចជាភាពអសកម្មដែលពួកគេបានជួបប្រទះ។

មានករណីតិចតួចបំផុត ដែលអ្នកទទួលខុសត្រូវ ត្រូវបានកាត់ទោស និងផ្តន្ទាទោស ជារឿយៗ កើតចេញពីលទ្ធផលនៃការតស៊ូមតិអស់រយៈពេលជាច្រើនឆ្នាំ ដើម្បីទទួលបានយុត្តិធម៌ និងដោយការលះបង់ផ្ទាល់ខ្លួនយ៉ាងច្រើនសម្រាប់ក្រុមគ្រួសារជនរងគ្រោះ។

និទណ្ឌភាពស្ទើរតែទាំងស្រុងនេះ រួមចំណែកដល់ការកើតឡើងវិញនៃការរំលោភបំពានបែបនេះ និងបរិយាកាសភ័យខ្លាចក្នុងចំណោមអ្នកសារព័ត៌មាន ក្រុមគ្រួសាររបស់ពួកគេ និងសង្គមទាំងមូល។

វិបត្តិជំងឺកូវីដ-១៩ បានស្តែងឱ្យឃើញកាន់តែច្បាស់ថា ការធ្វើរបាយការណ៍រិះគន់លើគោលនយោបាយរដ្ឋាភិបាល ឬឥស្សរជនសាធារណៈ ជារឿយៗ តែងត្រូវបានប្រឈមនឹងការចោទប្រកាន់។ ច្បាប់ដែលត្រូវបានអនុម័ត ឬអនុវត្ត ដើម្បីរឹតត្បិត និងដាក់ទោសព្រហ្មទណ្ឌចំពោះការផ្សាយព័ត៌មានមិនពិត ក្នុងអំឡុងពេលមានជំងឺរាតត្បាត ក៏ត្រូវបានប្រើប្រាស់ដោយរដ្ឋផ្សេងៗផងដែរ ដើម្បីកំណត់គោលដៅទៅលើអ្នកសារព័ត៌មាន។

នៅជុំវិញពិភពលោក ប្រជាជនបានចេញដើរតាមដងផ្លូវកាន់តែច្រើនឡើងៗ ដើម្បីទាមទារសិទ្ធិសេដ្ឋកិច្ច និងសង្គមរបស់ពួកគេ ក៏ដូចជា ការបញ្ចប់ការរើសអើង និងការប្រកាន់ពូជសាសន៍ជាប្រព័ន្ធ និទណ្ឌភាព និងអំពើពុករលួយ។ អ្នកសារព័ត៌មានបំពេញតួនាទីជាមូលដ្ឋានរបស់ខ្លួន ក្នុងការរាយការណ៍អំពីការតវ៉ាក្នុងសង្គមទាំងនេះ បានក្លាយជាគោលដៅដែលមិនអាចអត់ឱនបាន។ មនុស្សជាច្រើន បានរងគ្រោះដោយសារការប្រើប្រាស់កម្លាំងដែលមិនចាំបាច់ និងមិនសមាមាត្រ តាមរយៈការអនុវត្តច្បាប់ ការចាប់ខ្លួនដោយបំពាន និងការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ។

ការវាយប្រហារ ការចាប់ខ្លួន និងការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌប្រឆាំងនឹងអ្នកសារព័ត៌មាន មានឥទ្ធិពលភ័យខ្លាចបន្ថែមទៀត ដែលធ្វើឱ្យអ្នកសារព័ត៌មានដទៃទៀតមិនហ៊ានរាយការណ៍អំពីបញ្ហាពាក់ព័ន្ធ។ តាមវិធីនេះ ធ្វើឱ្យពួកគេថយចុះនូវការជជែកដេញដោលជាសាធារណៈ និងរារាំងសមត្ថភាពរបស់យើងក្នុងការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះបញ្ហាប្រឈមខាងសង្គម រួមទាំង ការរាតត្បាតនៃជំងឺកូវីដ-១៩។

ការងាររបស់អ្នកសារព័ត៌មាន និងបុគ្គលិកសារព័ត៌មាននឹងមានសារៈសំខាន់សម្រាប់ពិភពលោកស្តារឡើងកាន់តែប្រសើរពីការបំផ្លិចបំផ្លាញនៃវិបត្តិនេះ។ ព័ត៌មានដែលអាចជឿទុកចិត្តបាន ព័ត៌មានដែលបានពិនិត្យការពិត និងមានលក្ខណៈសត្យានុម័ត អាចប្រឆាំងនឹងការផ្សាយព័ត៌មានមិនពិត ជួយធានាបាននូវដំណោះស្រាយដែលធន់ និងប្រកបដោយចីរភាពចំពោះបញ្ហាប្រឈមនាបច្ចុប្បន្ននេះ ទាមទារឱ្យមានតម្លាភាព និងគណនេយ្យភាព ជំរុញឱ្យមានការជឿទុកចិត្តលើស្ថាប័ននានា។

រួមចំណែកដល់សុខុមាលភាពរបស់មនុស្សជាតិ ព័ត៌មានត្រឹមត្រូវ គឺជាផលប្រយោជន៍សាធារណៈ។ ការបំបិទសំឡេងអ្នកសារព័ត៌មានគឺជាការបាត់បង់ដល់សង្គមទាំងមូល។

ដើម្បីអបអរសាទរយ៉ាងពេញលេញនូវសេចក្តីក្លាហានរបស់អ្នកសារព័ត៌មាន ក្នុងការប្តេជ្ញាចិត្តរបស់ពួកគេ ដើម្បីផ្សព្វផ្សាយព័ត៌មានដល់សាធារណៈជន យើងត្រូវតែទាមទារឱ្យសិទ្ធិរបស់ពួកគេ ត្រូវបានគោរព ការពារ និងបំពេញ។